**សុន្ទរកថារបស់ បណ្ឌិត អ៊ីអ៊ីស៊ឹកា តូម៉ុហ៊ីរ៉ូ**
**លេខាទីពីរ ស្ថានទូតជប៉ុន**
**ថ្លែងក្នុងពិធីសម្ពោធគម្រោងសាងសង់កំពង់ផរខ្នាតតូច នៅឃុំកំពង់ស្រឡៅ១ ខេត្តព្រះវិហារ**
ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥

- **សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!**
- **សូមគោរព ឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ!**
- **សូមគោរព លោក សំ លាងទ្រី ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ!**
- **សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីចូលរួមក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការនៅថ្ងៃនេះ សម្រាប់គម្រោងសាងសង់កំពង់ផរខ្នាតតូច ក្នុងឃុំកំពង់ស្រឡៅ១ ខេត្តព្រះវិហារ ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុំ ម៉ារ៉ា** អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ និង**លោក សំ លាងទ្រី** ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ។

ការអភិវឌ្ឍវិស័យដឹកជញ្ជូន គឺមានសារៈសំខាន់ណាស់សម្រាប់លើកស្ទួយផ្នែកសេដ្ឋកិច្ច ក៏ដូចជាសកម្មភាពសង្គម ហើយនៅក្នុងបរិបទនៃប្រទេសកម្ពុជា ការដឹកជញ្ជូនតាមទន្លេនានា គឺពិតជាមានប្រសិទ្ធភាព និងប្រសិទ្ធផលយ៉ាងពិតប្រាកដ ហើយថែមទាំងមានសារៈសំខាន់មិនអាចខ្វះបានសម្រាប់ប្រជាជននៅមូលដ្ឋាន ដោយសារតែភាពសម្បូរបែបនៃប្រភពធនធានទឹក។

ដោយបានដឹងពីសារៈសំខាន់នៃវិស័យដឹកជញ្ជូន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលជប៉ុន បាននឹងកំពុងខិតខំប្រឹងប្រែងជួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការសាងសង់ផ្លូវថ្នល់ កំពង់ផែ និងស្ពានជាច្រើន។ យើងសង្ឃឹមថាគម្រោងនេះ នឹងជួយលើកស្ទួយសន្តិសុខមនុស្សជាតិជូនប្រជាពលរដ្ឋដែលងាយរងគ្រោះនៅក្នុងឃុំដែលពាក់ព័ន្ធផងដែរ ។

គម្រោងសាងសង់កំពង់ផរបេតុងខ្នាតតូចនេះ មានគោលបំណងកែលម្អនូវការដឹកជញ្ជូនតាមផ្លូវទឹកនៅតាមដងទន្លេមេគង្គ ដែលមានសារៈប្រយោជន៍សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងតំបន់ដែលពាក់ព័ន្ធ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ប្រជាពលរដ្ឋក្នុងឃុំកំពង់ស្រឡៅ១ ក៏ដូចជាប្រជាពលរដ្ឋទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធនៅថ្ងៃនេះ នឹងជួយថែទាំ និងស្រឡាញ់កំពង់ផរទាំងនេះ ចាត់ទុកជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជាសម្រាប់រយៈពេលជាច្រើនឆ្នាំទៅមុខទៀត។ ខ្ញុំក៏សង្ឃឹមថា កំពង់ផរខ្នាតតូចថ្មីទាំងនេះ នឹងរួមចំណែកក្នុងការលើកស្ទួយសេដ្ឋកិច្ចក្នុងតំបន់ តាមរយៈការលើកកម្ពស់ការធ្វើពាណិជ្ជកម្មរវាងត្រើយទាំងពីររបស់ទន្លេនេះ។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ ដែលបានរួមចំណែកធ្វើអោយការអនុវត្តគម្រោងនេះប្រព្រឹត្តទៅដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!